# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទថា ប្រទេសកម្ពុជាជាស្រុកឥតច្បាប់ បានជាស្រីខ្មែរលក់ស្រាបៀបានត្រូវជនពាលប្រមាថ មើលងាយគ្មានអាជ្ញាធរខ្មែរជួយការពារ

web site: hoksavann.org

ថ្ងៃទី២៤ មិថុនា ២០០៦

ព្រះពុទ្ធបានហាមមិនឲ្យមនុស្សលោកផឹកគ្រឿងស្រវឹងគ្រប់ប្រភេទ  មានស្រាជាដើម ដូចមានចែងក្នុងសិក្ខាបទទី៥នៃសីល៥ ថាជាទីតាំងនៃសេចក្ដីប្រមាថធ្វេសប្រហែស ព្រោះកាលណាស្រវឹងហើយ នាំឲ្យធ្វើការអ្វីមិនកើត ។ ព្រះពុទ្ធហាមផឹកគ្រឿងស្រវឹងនិងគ្រឿងញៀនគ្រប់ប្រភេទ មកពីមានទោស៦យ៉ាងគឺ ៖ ១- វិនាសទ្រព្យសម្បត្តិ, ២- បង្កើតជម្លោះ, ៣- កើតជម្ងឺ, ៤- ខូចកេរ្តិ៍ឈ្មោះ, ៥- បញ្ចេញកេរ្តិ៍ខ្មាស់, ៦- ខ្សោយបញ្ញា ។ ស្រាជាអំពើអបាយមុខ ជាប្រធាននៃការមិនចំរើន គឺតែងតែវិនាស ។ ប្រទេសកម្ពុជាជាប្រទេសគោរពព្រះពុទ្ធសាសនា គួរតែកុំផលិត កុំលក់កុំផឹកស្រាគ្រឿងស្រវឹងទាំងនេះ តែរាជរដ្ឋាភិបាលខ្មែរបានបើកដោយសេរី ព្រមទាំងបើកឲ្យផ្សាយពាណិជ្ជកម្មតាមវិទ្យុនិងទូរទស្សន៍ទៀតផង ។

ដោយស្រាជាអំពើអបាយមុខ បានជាកើតអំពើអសីលធម៌មួយទៀត គឺស្ត្រីខ្មែរដែលបំរើក្នុងស្រាបៀ  បានត្រូវជនពាលដែលទៅផឹកស្រា  បានប្រមាថមើលងាយដោយសំដីផង ប៉ះពាល់ដល់រាងកាយតាមផ្លូវកាមផង ថែមទាំងប្រើអំពើហឹង្សាទៅលើស្ត្រីទាំងនោះផង ។ ក្រៅពីប្រទេសកុម្មុយនិស្តនិងប្រទេសផ្ដាច់ការ, ប្រទេសដែលគោរពលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស តែងតែមានច្បាប់ទម្លាប់ការពារប្រជាពលរដ្ឋ ។ បើមានការរំលោភ តែងតែប្រឈមចំពោះមុខច្បាប់ គឺទាំងពលរដ្ឋទាំងអ្នកកាន់អំណាច ត្រូវនៅក្រោមច្បាប់ ។ ចុះហេតុអ្វីបានជាស្ត្រីខ្មែរ ដែលបំរើស្រាបៀត្រូវជនពាលជាបុរសរំលោភសិទ្ធិរបស់ខ្លួន គ្មានឃើញអាជ្ញាធរខ្មែរណាម្នាក់មកជួយការពារ ឬចាប់ជនពាលនោះទៅផ្ដន្ទាទោសឡើយ ។ មួយទៀត ក្រុមហ៊ុនស្រាបៀ

នោះទៀត បើកដៃឲ្យអតិថិជនជាជនពាលនោះ ប្រព្រឹត្តអំពើអសីលធម៌នេះតាមចិត្ត ដោយមានបំណងតែម៉្យាង គឺធ្វើយ៉ាងណាឲ្យតែលក់ស្រាបៀរបស់ខ្លួនដាច់បានច្រើន ។ តើឲ្យអាជ្ញាធរខ្មែរការពារស្ត្រីលក់ស្រាបៀនោះដូចម្ដេចកើត បើអាជ្ញាធរខ្លួនឯងនេះជាអ្នករំលោភ ។ តាមដំណឹងពីប្រទេសកម្ពុជាថា មានប៉ូលិសមហាផ្ទៃពីរបីនាក់បានរំលោភលើស្ត្រីលក់ស្រាបៀ រហូតប្រើអំពើហឹង្សាឲ្យមានរបួសទៀតផង ។

សូមស្ត្រីលក់ស្រាបៀដែលគេហៅមួយបែបទៀតរបៀបមើលងាយថា ស្រីឡង់សេ តាំងស្មារតីឲ្យរឹងមាំទប់ទល់នឹងជនពាល ដែលប្រមាថមើលងាយ កុំបណ្ដោយឲ្យជនពាលនោះប្រព្រឹត្តអំពើអសីលធម៌តាមបំណងរបស់វាឡើយ ។ សូមនាំគ្នាបង្កើតសហជីពកម្មកររបៀបសមាគម ដើម្បីឲ្យមានតំណាងសំរាប់ជួយការពារគ្នាពេលមានការរំលោភពីជនពាលនិងអំពីក្រុមហ៊ុន ។

អំពើមិនប្រក្រតីទាក់ទងនឹងកម្មករស្ត្រីលក់ស្រាបៀនេះ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនិងការងារ ត្រូវតែទទួលខុសត្រូវ បើច្បាប់មិនទាន់មានទេ ត្រូវតែធ្វើច្បាប់ឲ្យមានឡើង បើមានច្បាប់ហើយ ត្រូវតែអនុវត្តច្បាប់ ជាឧទាហរណ៍មនុស្សមកទិញស្រាបៀ ត្រូវតែប្រកាន់អាកប្បកិរិយាថ្លៃថ្នូរ មិនត្រូវប្រើភាសាអាសអាភាសរបៀបចែចង់ ឬគំរាមកំហែង ឲ្យបំរើខ្លួនខាងផ្លូវកាមគុណ បើមានសកម្មភាពបែបនេះ ត្រូវហៅប៉ូលិសមកចាប់ចង រួចឡើងតុលាការកាត់ក្ដី ។

មួយទៀត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចត្រូវធ្វើខសន្យាជាមួយក្រុមហ៊ុន បើមានអំពើអសីលធម៌នេះកើតឡើង ក្រុមហ៊ុនត្រូវទទួលខុសត្រូវ ។ ក្រុមហ៊ុនត្រូវតែរក្សាការពារហាមឃាត់កុំឲ្យអំពើនេះកើតឡើង ។ បើក្រុមហ៊ុនមិនយកចិត្តទុកដាក់ បណ្ដោយឲ្យអំពើនេះកើតឡើង ត្រូវតែហៅមកព្រមាន បើនៅតែមិនយកចិត្តទុកដាក់ទៀត អាចបិទរោងចក្រនោះតែម្ដង ។ ក្រុមហ៊ុនត្រូវផ្ដល់ប្រាក់ខែដល់ស្ត្រីទាំងនោះឲ្យបានសមរម្យ ហើយត្រូវបញ្ឈប់ការប្រើមធ្យោបាយលក់បានច្រើនឲ្យកំរៃច្រើន លក់បានតិចឲ្យកំរៃតិចដូច្នេះទៀត ព្រោះមធ្យោបាយនេះហើយ ដែលនាំឲ្យស្ត្រីខំប្រឹងប្រែងរហូតបណ្ដោយឲ្យអំពើថោកទាបកើតឡើងដល់ខ្លួន ។ ដើម្បីបំបាត់អំពើអសីលធម៌នេះឲ្យដល់ឫសគល់ មានតែបំបាត់អំពើអបាយមុខនេះតែម្ដង ព្រោះវាមានបញ្ហាដល់សង្គមច្រើនយ៉ាងណាស់ ។

ចាស់បូរាណខ្មែរបានទូន្មានបុរសៗថា បើឃើញស្ត្រីត្រូវទុកដូចជាម្ដាយ ឬទុកដូចជាបងឬប្អូនស្រីខ្លួនបង្កើត កុំប្រមាថមើលងាយ ឬចែចង់លួងលោមក្នុងផ្លូវកាមគុណ ។ ព្រះពុទ្ធសាសនាវិញពោលថា ទាំងបុរសទាំងស្ត្រីត្រូវសន្ដោសក្នុងកាម ប្ដីប្រពន្ធត្រូវស្មោះត្រង់នឹងគ្នាមួយនិងមួយ កុំលួចប្រពន្ធកូនប្ដីអ្នកដទៃ ដូចមានចែងក្នុងសិក្ខាបទទី៣នៃសីល៥ ។ អំពើថោកទាបរបស់បុរសខ្មែរខ្លះ ឲ្យតែឃើញស្ត្រីនិយាយចែចង់ បុរសគំរក់នេះ បើប្រព្រឹត្តការរំលោភទៀត ពុទ្ធសាសនាថា នឹងធ្លាក់ទៅសោយទុក្ខក្នុងនរក ឯផ្លូវលោកនឹងត្រូវទោសព្រហ្មទណ្ឌជាប់គុកជាយូរឆ្នាំ ។៚